01375509

លេខ: D225

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 10 / 01 / 2017
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des co-juges d'instruction

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧

ភាសា ៖ អង់គ្លេស & ខ្មែរ [អង់គ្លេស ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ សាធារណៈ

## សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**

អាង ឧត្តម
Michael G. KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Laure DESFORGES
Isabelle DURAND
Yiqiang LIU
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

## I. **ប្រវត្តិនីតិវិធី**

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ និង ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៤។

២. នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”) បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ ដោយបើកការស៊ើបសួរប្រឆាំង មាស មុត ហើយស្នើដាក់បទចោទផ្សេងៗប្រឆាំងគាត់[1]។ នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយចោទថា មាស មុត ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មបន្ថែមទៀត[2]។

៣. នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ បន្ទាប់ពីបានចុះហត្ថលេខាលើករណីខ្វែងយោបល់គ្នាជាមួយនឹង ស.ច.ស ជាតិ រួចមក អតីតចៅក្រមកាន់តំណែងខ្ញុំ បានដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យពីបទរំលោភលើមាត្រា ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦(មនុស្សឃាត) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត[3]។ នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ ខ្ញុំបានលុបចោលបទចោទមួយចំនួនដែលអតីតចៅក្រមកាន់តំណែងខ្ញុំបានចោទ មាស មុត ហើយខ្ញុំបានដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យពីបទប្រល័យពូជសាសន៍ បទចោទបន្ថែមទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់

---

[1]សំណុំរឿង ០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តកម្ពុជា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ កថាខណ្ឌ ៩៩។

[2]សំណុំរឿង ០០៣ ឯកសារ D120 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ២៥-២៧។

[3]សំណុំរឿង ០០៣ ឯកសារ D128 *ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ* ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥។ សំណុំរឿង ០០៣ ឯកសារ D128.1 *ការជូនដំណឹងអំពីបទចោទប្រឆាំង មាស មុត* ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥។

ធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភលើមាត្រា ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ (មនុស្សឃាត)[4]។

## II. ពិភាក្សា

៤. វិធានផ្ទៃក្នុង ៦៦(១) តម្រូវថា នៅពេលដែល ស.ច.ស យល់ឃើញថា ការស៊ើបសួរបានបញ្ចប់ហើយ ស.ច.ស ត្រូវជូនដំណឹងដល់គ្រប់ភាគី និងមេធាវីរបស់ភាគី។ បន្ទាប់មក ភាគីទាំងអស់ មានរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ ដើម្បីសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម ទោះបីជាភាគីទាំងអស់អាចលះបង់សិទ្ធិនេះក៏ដោយ។ ខ្ញុំបានសម្រេចពន្យាររយៈពេលនេះរហូតដល់ ៣០ ថ្ងៃ ។

៥. ខ្ញុំយល់ឃើញថា ការស៊ើបសួរប្រឆាំង មាស មុត បានបញ្ចប់ហើយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ៖**

៦. **ជូនដំណឹង** ភាគីទាំងអស់ និងមេធាវីរបស់ភាគីទាំងអស់ ថា ខ្ញុំយល់ឃើញថា ការស៊ើបសួរប្រឆាំង មាស មុត បានបញ្ចប់ហើយ។

៧. **ជូនដំណឹង** ភាគីទាំងអស់ ថា ភាគីទាំងអស់ អាចស្នើសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម ក្នុងរយៈពេល ៣០ ថ្ងៃ ទោះបីជាភាគីទាំងអស់អាចលះបង់សិទ្ធិនេះក៏ដោយ។

ភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**

[4] សំណុំរឿង ០០៣ ឯកសារ D174 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ មាស មុត* ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៥។